**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករគណនេយ្យនិងសវនកម្ម**

ថ្ងៃអង្គារ ៦រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង

## ស្តីពី

## ការជ្រើសរើសក្រុមហ៊ុន ឬវិទ្យាស្ថានវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម លើការបណ្តុះបណ្តាលស្តង់ដាគណនេយ្យសម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ

**និយ័តករគណនេយ្យនិងសវនកម្ម** (ន.គ.ស.) គឺជានិយ័តករ តែមួយគត់នៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលជាសេនាធិការឱ្យអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារលើការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មប្រកបដោយការជឿទុកចិត្តពីស្ថាប័នសាធារណៈ ស្ថាប័នឯកជន គណនេយ្យករ សវនករ និងសាធារណជន។ ដើម្បីអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន **ន.គ.ស.** បានដាក់ចេញនូវផែនការបណ្តុះបណ្តាលស្តង់ដាគណនេយ្យជូនដល់មន្ត្រីសាធារណៈពាក់ព័ន្ធ សហគ្រាសធុនធំ សហគ្រាសធុនតូចនិងមធ្យម និងអង្គភាពមិនស្វែងរកប្រាក់ចំណេញដើម្បីបញ្ជ្រាបការយល់ដឹងលើស្តង់ដាគណនេយ្យឱ្យបានទូលំទូលាយ ទាំងការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មស្របតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ដែលនឹងត្រូវធ្វើឡើងដោយក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ដែលមានគុណវុឌ្ឍិខ្ពស់លើវិស័យគណនេយ្យ និងសវនកម្ម។

ក្នុងន័យនេះ **ន.គ.ស.** សូមប្រកាសជ្រើសរើសក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដើម្បីផ្តល់សេវាបណ្តុះបណ្តាលស្តង់ដា CIFRS for SMEs និងស្តង់ដាគណនេយ្យសម្រាប់ NGOs។ ក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលត្រូវមានគុណវុឌ្ឍិ ដូចខាងក្រោម÷

### ១. លក្ខខណ្ឌគុណវុឌ្ឍិ

ក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលអាចចូលរួមក្នុងការដេញថ្លៃបានលុះត្រាតែជាក្រុមហ៊ុនដែល÷

- បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និងនៅអគ្គនាយកដ្ឋានពន្ធដារ ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- បានអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មពេញលេញ
- មានចំណេះដឹងអំពីស្តង់ដាគណនេយ្យ និងសវនកម្មដែលបានដាក់ឱ្យអនុវត្តជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា
- មានបទពិសោធន៍បណ្តុះបណ្តាលក្នុងវិស័យគណនេយ្យ និងសវនកម្មរយៈពេលយ៉ាងតិច ១០(ដប់)ឆ្នាំ
- ធ្លាប់បានចូលរួមក្នុងកិច្ចអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា ត្រូវបានលើកទឹកចិត្ត។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីមែល : info@acar.gov.kh
ទូរស័ព្ទ: ៨៥៥-២៣ ៨៨២ ១១១
Phone: 023 882 111

**២. សមិទ្ធផលដែលត្រូវផ្តល់**

ក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលទទួលជោគជ័យក្នុងការដេញថ្លៃ ត្រូវផ្តល់ជូន **ន.គ.ស.** នូវការបណ្តុះ-បណ្តាលស្តង់ដាគណនេយ្យសម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញដល់សិក្ខាកាម ដែលកំណត់ ដោយ **ន.គ.ស.** បានគ្រប់ចំនួន និងទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយភ្ជាប់បង្ហាញជាមួយនូវរបាយការណ៍ការបណ្តុះបណ្តាល។

**៣. កម្រៃ**

កម្រៃសម្រាប់ការបណ្តុះបណ្តាល គឺបើកចំហរសម្រាប់ការចរចារ។

**៤. រយៈពេលសម្រាប់ការបណ្តុះបណ្តាល**

ការបណ្តុះបណ្តាលស្តង់ដាគណនេយ្យខាងលើនេះមានរយៈពេលមិនលើស ២ (ពីរ) ខែ។ ក្នុងករណីមានការបន្ត ឬពន្យារពេលក្នុងការបណ្តុះបណ្តាលលើស ២ (ពីរ) ខែ នឹងត្រូវមានការពិភាក្សា និងចរចារ។

កិច្ចសន្យានៃការផ្តល់សេវាបណ្តុះបណ្តាលនឹងត្រូវបង្កើតឡើងរវាង **ន.គ.ស.** ជាមួយនឹងក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលបានទទួលជោគជ័យក្នុងការដេញថ្លៃ។

**៥. ការដាក់ពាក្យ**

ក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលមានចំណាប់អារម្មណ៍ សូមផ្ញើសេចក្តីចំណាប់អារម្មណ៍មក **ន.គ.ស.** តាមរយៈអ៊ីម៉ែល *b.tharin@acar.gov.kh និង n.bony@acar.gov.kh* ***ត្រឹមថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២១***។ ចំពោះក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលបានជាប់ក្នុងបញ្ជីសម្រាំងនឹងត្រូវបានជូនដំណឹងដើម្បីដាក់សំណើបច្ចេកទេស (Technical Proposal) និងសំណើហិរញ្ញវត្ថុ (Financial Proposal)។

សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមទាក់ទងតាមអាសយដ្ឋាន ឬលេខទូរស័ព្ទ ដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគារ "ក" ជាន់ទី១ ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- លេខទូរស័ព្ទទាក់ទង និងតេឡេក្រាម ÷ ០១២ ៧៩៣ ៣៩៨

**និយ័តករគណនេយ្យនិងសវនកម្ម**

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
សូមចូលរួមក្នុង Telegram Channel របស់
និយ័តករគណនេយ្យនិងសវនកម្ម